## ឈ្លើយសឹក (prisoner of war)

ឋានៈជាជនឈ្លើយសឹក មានចែងក្នុងអនុសញ្ញាហ្សឺណែវទី៣ (GC III) និង ពិធិសារបន្ថែម ទី១ (AP I) (មាត្រា ៤៣-៤៧)។ ឋានៈនេះផ្តល់ជូន អ្នកប្រយុទ្ធ (combatant) ដែលគោរព តាមលក្ខខណ្ឌអប្បបរមា ចែងក្នុងមាត្រាទាំងនោះ។ នេះសំដៅដល់អ្នកប្រយុទ្ធស្របច្បាប់ ទោះបីក្នុងលក្ខណៈទៀងទាត់ ឬមិនទៀងទាត់ក្តី ក៏នឹងទទួលបានឋានៈជាឈ្លើយសឹក។

ច្បាប់ បានប្រគល់ឋានៈជាឈ្លើយសឹក ដល់ជនស៊ីវិលផងដែរ ដែលគ្មានសិទ្ធិកាន់អាវុធ ក៏ប៉ុន្តែបានអមដំណើរជាមួយកងកម្លាំង។ នោះដូចជា សមាជិកក្នុងកប៉ាល់ រាប់បញ្ចូលទាំងនាវិក។ មានក្រុមមនុស្សផ្សេងទៀត ដែលមិនមានឋានៈជាឈ្លើយសឹក ដូចជា ចារកម្ម (spy) ក៏ប៉ុន្តែទទួលបានការប្រព្រឹត្ត ដូចជាឈ្លើយសឹក។

ឈ្លើយសឹក ទទួលបានការគោរព សេចក្តីថ្លៃថ្នូរ គ្រប់កាលៈទេសៈ និងត្រូវបានប្រព្រឹត្តក្នុងលក្ខណៈមនុស្សធម៌ (human treatment)(មាត្រា ៣៣ នៃអនុសញ្ញាហ្សឺណែវ ទី៣)។ ឈ្លើយសឹក មានកាតព្វកិច្ចផ្តល់នូវឈ្មោះ អាចត្រូវបានសួរចម្លើយ ក៏ប៉ុន្តែ មិនត្រូវបានជាកម្មវត្ថុនៃការសងសឹក (reprisal)។ ពួកគេត្រូវបានឃុំ នៅឆ្ងាយពីទីតាំងប្រយុទ្ធ។

ឈ្លើយសឹក មិនត្រូវបានបង្ខំឲ្យបោះបង់សិទ្ធិចែងក្នុងមាត្រា ៧ នៃអនុសញ្ញាហ្សឺណែវទី៣ទេ ហើយវិធានទាំងនេះ មិនត្រូវផ្អាកអនុវត្តឡើយ (non-derogable)។ ការរត់គេចខ្លួន មិនត្រូវជាបទល្មើសព្រហ្មទណ្ឌ ហើយនៅពេលចាប់បាន មានតែទណ្ឌកម្មពិន័យប៉ុណ្ណោះ ត្រូវបានអនុវត្ត។ ក្នុងករណី ដែលការជម្លៀសមិនអាចទៅរួច ហើយការដោះលែងជាជម្រើសនោះ លក្ខខណ្ឌសុវត្ថិភាពរបស់ពួកគេ ត្រូវបានធានា។

ការបំពាន សិទ្ធិចម្បងរបស់ឈ្លើយសឹក ដូចជាការសម្លាប់ដោយចេតនា (willful killing) ទារុណកម្ម (torture) ឬទង្វើអមនុស្សធម៌ (inhuman acts) គឺជាបទឧក្រិដ្ឋកម្មសង្គ្រាម (war crime) (Antonio Cassese, the Oxford Companion to International Criminal Justice, 2009, pp. 462-464)។